ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២៣៤៥ ព.ណ.ករ....

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្រុមប្រឹក្សាជំរុញការនាំចេញផ្នែកវិស្វកម្មឥណ្ឌា (EEPC) ដែលគាំទ្រដោយក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា នឹងរៀបចំពិធីតាំងពិព័រណ៍ផ្នែកសិប្បកម្ម និងឧស្សាហកម្ម ឆ្នាំ២០២១ " Metal Cutting, Forming & Welding EXPO 2021" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៨ ដល់ ២៩ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ។

ក្នុងឱកាសនៃការរៀបចំពិព័រណ៍នេះ ក្រុមប្រឹក្សាជំរុញការនាំចេញផ្នែកវិស្វកម្មឥណ្ឌា (EEPC) សូមអញ្ជើញក្រុមហ៊ុនកម្ពុជា ដែលកំពុងធ្វើធុរកិច្ចលើផ្នែកសិប្បកម្ម និងឧស្សាហកម្មពាក់ព័ន្ធនឹងការកាត់ ផ្សារ តម្លើងដែក ដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ និងចូលរួមកម្មវិធីជំនួបពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញ (Webinars – B2B) នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១។ ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល ជាមួយស្ថានទូតឥណ្ឌាប្រចាំនៅភ្នំពេញ សូមអញ្ជើញលោក លោកស្រីដែលជាសិប្បករ ឧស្សាហករ និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមចូលទៅគេហទំព័រ https://eepcvirtualexpo.com/metalcutting-2021 ឬ បំពេញបែបបទចុះឈ្មោះចូលរួមតាមរយៈ https://eepcvirtualexpo.com/visitor/ovex visitor registration form/MjM ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ៖ ០១៧ ៩៦០ ២០០ / ០៨៧ ៧៥៥ ៥៥១ ឬអ៊ីម៉ែល៖ chousetha@gmail.com/ ritatong19@gmail.com។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម